ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-១២-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ហួទូ** (LIU HUO-TU) ជនជាតិចិន សញ្ជាតិបួគីណាហ្វាសូ កើតនៅប្រទេសចិន ០០១

០៩-១២-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៨៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លូយ ហ្ស៊ុងលូ** (LU ZHONGLOU) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តសាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន ០០២

០៩-១២-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៨៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **សេ យិត យូ** (TSE YUET YU) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ០០៣

១៦-១២-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៩៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **គុំ សូន គីម** (KIM KUM SOON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ០០៤

១៦-១២-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៩៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ង យ៉ានអ៊ី** (WANG YANYU) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តសានដុង សាធារណរដ្ឋប្រជាមានិតចិន ០០៥

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១០៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ០០៦

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១០៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជូនឧត្តមសេនីយ៍ឯក **នួន សុខ** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ០០៧

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **គិត ម៉េង** ០០៨

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១០៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈឹង យីនយីម** (CHENG YING YIM) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ០០៩

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី ចិន ហ្ស៊ីហុង (CHEN ZHIHONG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្ដូរឈ្មោះជា ឈិន ហុង (CHEN HONG) ០១០

២១-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្ដម ចំនួន ០៣ រូប ០១១

២២-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ជាកិច្ចបច្ឆាមរណៈ ចំពោះ ឯកឧត្ដមឧកញ៉ា ម៉ែន សារុន ០១២

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៤ ស្ដីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ចំនួន ០៩ រូប ក្នុងឋានន្តរស័ក្ដិឧត្ដមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម ០១៣

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ មន្ត្រីរាជការ នៃក្រសួងបរិស្ថាន ចំនួន ០៣ រូប ០១៥

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៧-១២-២០១១-អនុក្រឹត្យលេខ ២៩២ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ០១៦

២៨-១២-២០១១-អនុក្រឹត្យលេខ ២៩៣ អនក្រ.បក ស្ដីពី ការទទួលស្គាល់វិទ្យាស្ថានខ្មែរជំនាន់ថ្មី ០១៨

៣០-១២-២០១១-អនុក្រឹត្យលេខ ២៩៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ០២១

២៧-១២-២០១១-អនុក្រឹត្យលេខ ១៣៣៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ០២៣

២៧-១២-២០១១-អនុក្រឹត្យលេខ ១៣៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ០២៤

២៧-១២-២០១១-អនុក្រឹត្យលេខ ១៣៣៨ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ០២៥

២៧-១២-២០១១-អនុក្រឹត្យលេខ ១៣៣៩ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ០២៦

២៧-១២-២០១១-អនុក្រឹត្យលេខ ១៣៤០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ០២៧

២៨-១២-២០១១-អនុក្រឹត្យលេខ ១៣៤១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ០២៩

២៨-១២-២០១១-អនុក្រឹត្យលេខ ១៣៤២ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ០៣៣

III. ការិយាល័យ/ក្រសួង

១. ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-១២-២០១១ -ប្រកាសលេខ ១១០៩ សហវ.ប្រក ស្ដីពី ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចាត់វិធានការចុះត្រួតពិនិត្យ និង បង្ក្រាបទីតាំងអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដែលគ្មានអាជ្ញាប័ណ្ណពីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ០៣៦

២. ធនាគារជាតិ នៃ កម្ពុជា

៣០-១២-២០១១ -ប្រកាសលេខ ធ ១២.០១១.២៤៦ ប្រក ស្ដីពី ការបង្កើតក្រុមការងារពិគ្រោះយោបល់ស្ដីពីការប្រតិបត្តិតាមការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ០៣៩

៣. ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៥-១២-២០១១ -ប្រកាសលេខ ៦១០ ប្រក.កសក ស្ដីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ ព្រៃសហគមន៍ក្នុងខេត្តកំពត ០៤២

០៥-១២-២០១១ -ប្រកាសលេខ ៦១១ ប្រក.កសក ស្ដីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ ព្រៃសហគមន៍ក្នុងខេត្តតាកែវ ០៥៦

០៥-១២-២០១១ -ប្រកាសលេខ ៦១២ ប្រក.កសក ស្ដីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ ព្រៃសហគមន៍ក្នុងខេត្តកែប ០៧៤

៤. ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

០៨-១២-២០១១ -ប្រកាសលេខ ១១១ ប្រក ស្ដីពី ការរៀបចំស្ថិតិទេសចរណ៍ ០៨១

៥. ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២២៩ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **គីនហ្គ ប៊ី.ឌី ខូអូ អ៊ិនធើថេនមេន** ០៨៥

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៣០ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អ៊ីសធើន រ៉ាប់ប៊ើ (ខេមបូឌា)** ០៨៧

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៣៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូគីម៉ិច អ៊ិនវេសមេន គ្រុប** ០៨៩

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៣៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **2 ជីអិល ហ្គោលម៉ាញ** ០៩១

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ដេវ ខេម.គ្រុប** ០៩៣

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សត្យា ឌីវេឡុបមេន** ០៩៥

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៤៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយ ថុង អ៊ិនធើណេសិនណល** ០៩៧

១៧-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីឌីខេធេល ខូ អិលធីឌី** ០៩៩

១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **អេនហ្សូ អ៊ិនវេសមេន,អិល.ភី** ១០១

១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ការិយាល័យតំណាងពាណិជ្ជកម្ម ក្រុមហ៊ុន **ប៉ាណាសូនិច ខបភើរេសិន** ១០២

១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ៀប ហូលឌីង លីមីធីត** ១០៣

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **លីវ ហួទូ** (LIU HUO-TU) ជនជាតិចិន សញ្ជាតិបួគីណាហ្វាសូ កើតថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥៨ នៅប្រទេសចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១១១៧.១១០៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៤២ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១០៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លូយ ហ្សុងលូ** (LU ZHONGLOU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៦៥ នៅខេត្តសាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible].១១១២.១១០៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១

បានឃើញ ១០៩៦ច.ល
ដើម្បីចម្លងចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១០៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **សេ យិត យូ** (TSE YUET YU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៥៩ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៨.១១១២.១១០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១១

លេខ: ១០៤៣ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ .ថ្ងៃទី ១៤ ខែ: ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **គុំ សូន គីម** (KIM KUM SOON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៤០ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារស. ១១១៧. ១១១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៥៩ ប.ល
ចម្លងចែក
ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១០៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង យ៉ានអ៊ី** (WANG YANYU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៦៣ នៅខេត្តសានដុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៤.១១១៥.១១១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១

លេខៈ ១០៦០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ [illegible] ឆ្នាំ២០១១
[illegible]ទីស្តីការគណៈរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

ក. ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក

- ឧត្តមសេនីយ៍ទោ **ពោជ ខេន** អត្តលេខ ០០១៣៥៥

ខ. ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី

- វរសេនីយ៍ឯក **ស្រេង ហុង** អត្តលេខ ០០០៨៥៥

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៨/ទក.១១១២.១១២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

លេខ: ១០៤៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **នាយឧត្តមសេនីយ៍ផ្កាយមាស ៤** ជូនឧត្តមសេនីយ៍ឯក **នួន សុខ** អត្តលេខ ០០០០១១ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៤.១១១២-១១២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៧៥ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ធ្នូ ឆ្នាំ២០១១
[illegible]ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧកញ៉ា **គិត ម៉េង**

ដែលមានស្នាដៃល្អ ក្នុងការដឹកនាំសភាពាណិជ្ជកម្មកម្ពុជា ជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្មបានល្អប្រសើរ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការស. ១១១២. ១១២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៧៣ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈើង យីងយឹម** (CHENG YING YIM) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៥១ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ជាទណ. ១១១២-១១៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៧៣ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១១
អគ្គ[illegible]ការ[illegible]ទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចិន ហ្ស៊ីហុង** (CHEN ZHIHONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៧៣ នៅខេត្តក្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ឈិន ហុង** (CHEN HONG)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរសេ.១១១២.១១៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៧៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១១
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

- ឯកឧត្តម ម៉ម សារិន
- ឯកឧត្តម គាត ស៊ុនអ៊ី
- ឯកឧត្តម សោម សឿន

ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ ។

នរោត្តម សីហមុនី

នរោត្តម សីហមុនី

៣៣៤.១១៦២.១១៣៣

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ ..../១១ ព.ចប

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធរា គង់ សំអុល

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះបរ...

MINISTÈRE DU PALAIS

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិត្តិយសបច្ឆាមរណៈ

ចំពោះសព

ឯកឧត្តមឧកញ៉ា ម៉ែន សារុន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

នរោត្តម សីហមុនី

នរោត្តម សីហមុនី

៣៩៨. ១១១២. ១១៣៤
បានប្រជាប់ព្រះរាជលញ្ឆករហើយ
ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ...០២/១១... រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ...ខែ... ឆ្នាំ ២០១១
សម្តេចចៅហ្វាវាំង អធិបតីឧត្តមប្រឹក្សា គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE — MINISTÈRE DU PALAIS ROYAL

ព្រះរាជក្រឹត្យ

នស/រកត/០២១១/១១១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការចំនួន ០៩ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១៖

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ថ្នាក់ស្នើសុំ
១	**ឈួន ដារ៉ា**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២	**ម៉ក់ ពេជ្ររិទ្ធ**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៣	**ឃឹម សិរីវឌ្ឍ**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៤	**លី ផាណ្ណា**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៥	**ពេជ្រ បុទ្ធី**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៦	**សុខ [illegible]**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៧	**[illegible]ន សុ[illegible]**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨	**ហាច្យ ម៉ើន**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៩	**ជួន ឆន**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥

មាត្រា២ .. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៤ .. ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១២១១/១១៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៩៣ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនៃក្រសួងបរិស្ថាន ចំនួន០៣រូប ដែលមានស្នាដៃល្អខិតខំបំពេញភារកិច្ច ស្តីពីកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-ឯកឧត្តម ឈុន ប៊ុនលី
២-ឯកឧត្តម ស្រី ស៊ីណា
៣-ឯកឧត្តម ទ៉ាន់ សឿន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១១១២-១១៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១

លេខ:១០៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១១
អគ្គលេខាធិការ[illegible]ទី១រាជរដ្ឋាភិបាល
ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ២៩២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៤ ៥៤១ ៦០០ ០០០រៀល(បួនពាន់ប្រាំរយសែសិបមួយលានប្រាំមួយរយពាន់រៀលគត់)ពីជំពូក០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) របស់ក្រសួងពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់បុរេប្រទានលើការទិញអង្ករដោយក្រុមហ៊ុនគ្រីនត្រេដ ចំនួន ២ ០០០តោន។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៩៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់វិទ្យាស្ថានខ្មែរជំនាន់ថ្មី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពី ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា ១ : ទទួលស្គាល់វិទ្យាស្ថានខ្មែរជំនាន់ថ្មី ដែលមានអក្សរកាត់ " វ.ខ.ថ. " និងជាភាសាអង់គ្លេសថា Institute of New Khmer ដែលមានអក្សរកាត់ " I.N.K "។ វិទ្យាស្ថាននេះ ស្ថិតនៅ

ក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅអគារលេខ១៤០ ផ្លូវលេខ ២៥៣ ភូមិ១២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មាត្រា ២ : វិទ្យាស្ថានខ្មែរជំនាន់ថ្មី មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិញ្ញាបនបត្រ សិក្សារយៈពេលយ៉ាងតិច ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ ត្រូវនឹង ៣០ក្រេឌីតឡើងទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ០២ឆ្នាំ ត្រូវនឹង ៦០ក្រេឌីតឡើងទៅ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច០៤ឆ្នាំ ត្រូវនឹង១២០ក្រេឌីតឡើងទៅ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សាយ៉ាងតិចរយៈពេល០២ឆ្នាំ ត្រូវនឹង៤៥ក្រេឌីតឡើងទៅ។

មាត្រា ៣ : ចំពោះមុខ វិទ្យាស្ថានខ្មែរជំនាន់ថ្មី មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យបច្ចេកទេស
- ការិយាល័យសិក្សា
- ការិយាល័យផែនការ និង ហិរញ្ញវត្ថុ
- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និង ភាសា
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
- មហាវិទ្យាល័យវិស្វកម្ម និង វិទ្យាសាស្ត្រកុំព្យូទ័រ

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៤: លក្ខខណ្ឌទទួលសិស្ស-និស្សិត ឲ្យចូលរៀន ៖

- ថ្នាក់វិញ្ញាបនបត្រ បេក្ខជនជាសិក្ខា កាមសិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនមានសញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋាននានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស និស្សិត។

មាត្រា ៥: វិទ្យាស្ថានខ្មែរជំនាន់ថ្មី មាននាយកមួយរូប និង មាននាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យបានទៀងទាត់តាមការកំណត់។

មាត្រា ៦: សិស្ស-និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ នឹងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឲ្យដោយវិទ្យាស្ថានខ្មែរជំនាន់ថ្មី នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៧: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៨: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានខ្មែរជំនាន់ថ្មី ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ២៩៤ -អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៥ ៣៨២លាន រៀល(ប្រាំពាន់បីរយប៉ែតសិបពីរលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦០ (ការទិញ) ចំនួន ២ ០៣៧ ៩៣៣ ០០០រៀល ជំពូក៦១ (សេវាខាងក្រៅ) ចំនួន១ ៨៥៥ ៥៣២ ០០០ រៀល និងជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន១ ៤៨៨ ៥៣៥ ០០០រៀល របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់បុរេប្រទានឥណទានថវិកាលើចំណាយទូទៅត្រីមាស ទី៤ ឆ្នាំ ២០១០ របស់ស្ថានតំណាងកម្ពុជា ប្រចាំបរទេស។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧៦.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ចំនួន ០៦គ្រឿង ជូនសប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាង អាគារបណ្ណាល័យនៅអនុវិទ្យាល័យព្រែកដំបង ០១ខ្នង ទទឹង ០៨ម៉ែត្រ និងបណ្តោយ ១៦ម៉ែត្រ ស្ថិតនៅក្នុងភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

ក-មេដាយប្រាក់ស្ថាបនាជាតិ

១-	អនុសេនីយ៍ទោ	**គីម យ៉ាឌី** អត្តលេខ ៦៧៩១៨	មន្ត្រីនគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែត	ថវិកា ៦.២០០ ដុល្លារ
២-	អនុសេនីយ៍ឯក	**មាស ឧុទ្ធី** អត្តលេខ ០៥៥៥៤	ប្រធានផ្នែកនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ	ថវិកា ៦.១៥០ ដុល្លារ
៣-	អនុសេនីយ៍ទោ	**សោម ម៉ានី** អត្តលេខ ១៦២០៩	អនុប្រធានផ្នែកនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ	ថវិកា៦.០៥០ ដុល្លារ

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ

១-	លោក	ឈាន ឈឺន	សប្បុរសជន	ថវិកា ៣.២០០ ដុល្លារ
២-	លោក	ម៉ិន តារម្យ	សប្បុរសជន	ថវិកា ៣.០៥០ ដុល្លារ
៣-	លោក	រស់ សុវណ្ណារ័ត្ន	សប្បុរសជន	ថវិកា ៣.០៥០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៣៧.អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ចំនួន ០២គ្រឿង ជូនសប្បុរសជន នៅក្រៅប្រទេស ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារនៅវត្តកោះគល់ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដូចមាននាមខាងក្រោម ៖

១- លោក **តាន់ គីមហួរ** សប្បុរសជននៅប្រទេសបារាំង
២- លោក **ហ្វ្រង់ស្វ័រ ហ្គារហ្ស៊ែរ** សប្បុរសជននៅប្រទេសបារាំង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **ចាន់ សុជាវី** ឲ្យបំពេញមុខងារជាអធិការ នៃអគ្គាធិការដ្ឋានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនគ្រឿងឥស្សរិយយសសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តប្រជាសង្គមភ្នំក្រពើ** ស្ថិតនៅក្នុងឃុំប្រាសាទភ្នំខ្យង ស្រុកកំពង់ត្រាច ខេត្តកំពត ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណ **ខៀវ បូរ៉ា** ព្រះចៅអធិការវត្តប្រជាសង្គមភ្នំក្រពើ បច្ច័យចំនួន ៣១.០០០ ដុល្លារ

២-Mr. FRANCIS IAN MURRAY សប្បុរសជននៅប្រទេសអូស្ត្រាលី ថវិកាចំនួន ៣០.៨១០ ដុល្លារ

មាត្រា ២.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ១២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យ ព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តប្រជាសង្គមភ្នំក្រពើ** ស្ថិតនៅក្នុងឃុំប្រាសាទភ្នំខ្យង ស្រុកកំពង់ត្រាច ខេត្តកំពត ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

ក- មេដាយមាសស្ថាបនាជាតិចំនួន ០២ គ្រឿង ប្រគេន និងផ្តល់ជូន :

១- ព្រះតេជគុណ **ឆន់ សុខុំ**	គង់នៅវត្តជោតិរង្សី ខេត្តកណ្តាល	បច្ច័យចំនួន ១០.០៥០ ដុល្លារ
២-លោក **តាន់ សាវ៉ាទុច**	សប្បុរសជននៅខេត្តកំពត	ថវិកាចំនួន ១០.០០០ ដុល្លារ

ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-ឧបាសិកា **មេ គីមហ្គិច**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.៣១០ ដុល្លារ
២-លោកវរសេនីយ៍ត្រី **ហាន សុផល**	ប្រធានប៉ុស្តិ៍ច្រកទ្វារអន្តរជាតិព្រែកចាក	ថវិកាចំនួន ៥.០៥០ ដុល្លារ
៣-លោក **ហ៊ុន តេង**	មេឃុំប្រាសាទភ្នំខ្យង	ថវិកាចំនួន ៥.០០០ ដុល្លារ

គ- មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៧ គ្រឿង ផ្តល់ជូន :

១-លោកស្រី **សូ អ៊ី**	សប្បុរសជនខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ១.២២០ ដុល្លារ
២-លោកស្រី **ចន ប៊ុណ្ណា**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.១២០ ដុល្លារ

៣-លោក **ខូច មាន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១.០០០ ដុល្លារ
៤-លោក **ប្រាក់ សិទ្ធិសិលា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១.០០០ ដុល្លារ
៥-លោក **យ៉ង់ សារី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១.០០០ ដុល្លារ
៦-លោក **អ៊ុច ស៊ុំ**	នាយកអនុវិទ្យាល័យភ្នំខ្យង	ថវិកាចំនួន ១.០០០ ដុល្លារ
៧-លោក **អ៊ុន អាន**	សប្បុរសជននៅខេត្តកំពត	ថវិកាចំនួន ១.០០០ ដុល្លារ

មាត្រា ២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពត និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៣៤១ .អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

